**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខៈ ១០៤ ប្រ.ក...សក.ជជ

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១០

លិខិតចូល
ថ្ងៃទី២៦...ខែ០៣...ឆ្នាំ២០១០

# ប្រកាស

## ស្តីពី

## ការកំណត់ការប្រើប្រាស់ដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ជាប្រយោជន៍សាធារណៈ និងឯកជន

## រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើង នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួង។

## សម្រេច

**ប្រការ ១ ៈ-**

ប្រកាសនេះ មានគោលដៅពង្រឹងការអនុវត្តបទប្បញ្ញត្តិ ដែលកំណត់ដោយអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២ .-**

ដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើងជាចំរៀកដីសងខាងអ័ក្សនៃផ្លូវជាតិ និងផ្លូវរថភ្លើងដែលបម្រុងទុកស្របតាមបទដ្ឋានបច្ចេកទេសដូចមានចែងក្នុងមាត្រា៨ និងមាត្រា៩ នៃអនុក្រឹត្យលេខ ១៩៧អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា ហើយស្ថិតក្រោមការគ្រប់គ្រង និងការទទួលខុសត្រូវដោយផ្ទាល់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ ៣ .-**

រាល់សកម្មភាពដែលបង្កខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធផ្លូវជាតិនិងផ្លូវរថភ្លើង តាមរយៈការទន្ទ្រានកាន់កាប់ ការសាងសង់ ការដាំបង្គោល ការវាយបណ្តាញ ការជីកគាស់ កាប់កកាយ ការចោះខួង ឬការធ្វើឱ្យបែកបាក់ផ្ទៃមុខខាងលើ និងក្រោមដីចំណី ការដាក់គរកម្ទេចកម្ទី អាចម៍ដី ខ្សាច់ ឬការលុបបំពេញ ការដាក់តាំងសម្ភារៈ ផ្លាកសញ្ញា ឬរចនាសម្ព័ន្ធផ្សេងៗ (ក្នុងដី លើដី និងក្នុងលំហ) ក្នុងដែនកំណត់ដីចំណីផ្លូវថ្នល់ និងផ្លូវរថភ្លើង ដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចជំនាញ ត្រូវហាមឃាត់។

**ប្រការ ៤ .-**

ការប្រើប្រាស់ដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើងសម្រាប់ប្រយោជន៍សាធារណៈនិងឯកជនជាអាទិ៍ ការជីកកប់បណ្តាញខ្សែកាបអុបទិក បំពង់ទឹកស្អាត ការបោះបង្គោលខ្សែកាបអុបទិក ការបោះបង្គោលអគ្គិសនី ការបោះបង្គោលផ្សាយពាណិជ្ជកម្ម និងការប្រើប្រាស់ផ្សេងទៀតទាក់ទងនឹងដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងសាធារណការ និងដឹកជញ្ជូន។ សកម្មភាពនេះអាចធ្វើទៅបានបន្ទាប់ពីទទួលបានលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រសួងសាធារណការ និងដឹកជញ្ជូន ដោយចាត់វិធានការការពារសណ្តាប់ធ្នាប់ ការកកស្ទះចរាចរណ៍ ឬឧបទ្ទវហេតុផ្សេងៗ និងការពារបរិស្ថានឱ្យបានត្រឹមត្រូវ និងត្រូវគោរពតាមការណែនាំរបស់សមត្ថកិច្ចជំនាញ។

**ប្រការ ៥ .-**

ការសាងសង់តំបន់ថ្មីៗជាអាទិ៍ តំបន់ទីក្រុង តំបន់ឧស្សាហកម្ម តំបន់សេដ្ឋកិច្ចពិសេស តំបន់ទីប្រជុំជន តំបន់ពាណិជ្ជកម្ម តំបន់ទេសចរណ៍ និងតំបន់ផ្សេងទៀត ត្រូវធ្វើការសាងសង់នៅខាងក្រៅដែនកំណត់ដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង និងត្រូវមានប្រព័ន្ធផ្លូវរួមដែលស្ថិតនៅខាងក្រៅដីចំណីផ្លូវ និងមានគម្លាតតាមការកំណត់ដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង។

**ប្រការ ៦ .-**

អគ្គនាយកដ្ឋានសាធារណការ ត្រូវសហការជាមួយសមត្ថកិច្ចជំនាញពាក់ព័ន្ធ ដើម្បីធ្វើការណែនាំ និងផ្សព្វផ្សាយអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាព អ្នកប្រើប្រាស់ផ្លូវ និងប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ដើម្បីចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព។

**ប្រការ ៧ .-**

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត មានភារកិច្ចទទួលខុសត្រូវតាមដានការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងចុះត្រួតពិនិត្យរាល់សកម្មភាពដែលទាក់ទងនឹងការប្រើប្រាស់ដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងករណីពិនិត្យឃើញមានការរំលោភបំពានលើដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង ត្រូវផ្អាកសកម្មភាពទាំងនោះជាបន្ទាន់ និងរាយការណ៍មកក្រសួងសាធារណការ និងដឹកជញ្ជូន និងសាលារាជធានី ខេត្ត ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

**ប្រការ ៨ .-**

ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩ .-**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកសាធារណការ អគ្គនាយកដឹកជញ្ជូន អគ្គាធិការ លោកប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង និងប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ត្រាំ អ៊ីវតឹក

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ